00398880

លេខ / No: D194/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 11 / 2009
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 06 / 11 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងលេខ ៖ 002/19-09-2007-អ.វ.ត.ក.-ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

កាលបរិច្ឆេទ៖ ០៥ វិច្ឆិកា ២០០៩

ភាសាដើម៖ ខ្មែរ /បារាំង

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# ដីកាសម្រេច លើសំណើសុំធ្វើប្រតិចារឹក

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង
លោក William SMITH

**ជនត្រូវចោទ**

នួន ជា ខៀវ សំផន អៀង សារី
អៀង ធីរិទ្ធ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី
ឡោ ឈុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
ស៊ីន សុវន
Silke STUDZINSKY
Phillipe CANONNE
Marie Guiraud
Elizabeth Rabesandratana
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David BLACKMAN
Martine JACQUIN
Annie DELAHAIE
Fabienne TRUSSES-NAPROUS
Patrick BAUDOIN
Lyma Thuy Nguyen

**មេធាវីការពារក្តី**

សុន អារុណ Michiel PESTMAN
Victor KOPPE
អាង ឧត្តម Michael G. KARNAVAS
ផាត់ ពៅស៊ាង Diana ELLIS
ស សុវ៉ាន់ Jacques VERGES
ការ សាវុត្ថ Francois ROUX
Me. Marie-Paule CANIZARES

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក”)

បានឃើញការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនផ្សេងទៀត ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃ ទី ១២ ខែសីហា ឆ្នាំ ១៩៤៩** បទល្មើស ដែល មានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក

បានឃើញវិធាន ២៥ និងវិធាន ៥៥(៧) និង (១០) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ (“វិធានផ្ទៃក្នុង”)

បានឃើញ សំណើលើកទី ១៤ សុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០០៨ (សំណើសុំ D194)

## ការរំលឹកឡើងវិញពីនីតិវិធី និងការកត់សំគាល់របស់មេធាវីការពារក្តី

១. នៅក្នុងសំណើសុំចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨ ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ក្រាំងតាចាន់ សហព្រះរាជអាជ្ញា បានសំអាងលើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាច្រើន ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស) ដើម្បីគាំទ្រថា នួន ជា បានចុះទៅពិនិត្យមន្ទីរនេះ នៅពេលខុសៗគ្នា[1]។

២. នៅក្នុងសំណើសុំរបស់ខ្លួន មេធាវីការពារក្តី នួន ជា លើកឡើងពីភាពខុសគ្នារវាងកំណត់ហេតុស្តាប់ចម្លើយពីររបស់សាក្សីមួយរូបដែលសហព្រះរាជអាជ្ញាយកមកសំអាង និងស្នើសុំ

---

[1] ឯកសារលេខ D183 សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទិននឹងមន្ទីរសន្តិសុខក្រាំងតាចាន់ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៨។

00398882



សហចៅក្រមស៊ើបអង្កេត បង្គាប់ឲ្យមានការធ្វើប្រតិចារឹកត្រង់ៗតាមពាក្យពេចន៍ (បន្ទាប់មកបកប្រែជាភាសាអង់គ្លេស) នៃខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយទាំងនេះ។ ដោយរំលឹកពីអនាគតិភាពរបស់សហចៅក្រមស៊ើបអង្កេត មេធាវីការពារក្តី ធ្វើសំណើរបស់ខ្លួនដោយសំអាងទៅលើសារៈសំខាន់នៃការផ្តល់សក្ខីកម្មនេះសម្រាប់កូនក្តីរបស់ខ្លួន និងការបញ្ជាក់អះអាងថា *"ចំនុចនេះ វាមិនច្បាស់លាស់ត្រង់ ថាតើទម្រង់កំណត់ហេតុផ្តល់ចម្លើយបច្ចុប្បន្នរបស់ [សាក្សី] វាតំណាងឲ្យសក្ខីកម្មត្រឹមត្រូវនូវអ្វីដែលសាក្សីបាននិយាយជាមួយនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដែរ ឬក៏ទេនោះ"* (កថា. ៩) ។

៣. ម្យ៉ាងទៀត សំណើសុំ អះអាងថា អ្នកស៊ើបអង្កេត *"មិនបានដាក់បញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួនដែលដាក់ជូនសហចៅក្រមស៊ើបអង្កេត នូវភស្តុតាងដែលមានលក្ខណៈដោះបន្ទុកជនត្រូវចោទទេ"* (កថា. ៧)។

## សំអាងហេតុនៃសេចក្តីសម្រេច

៤. សហចៅក្រមស៊ើបអង្កេតមានមធ្យោបាយនីតិវិធីជាច្រើនដើម្បីបំភ្លឺពីសក្ខីកម្មដែលមានលក្ខណៈផ្ទុយគ្នា ទៅតាមការផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមការសំណើរបស់ភាគី៖ ជាពិសេស ខ្លួនមានលទ្ធភាពក្នុងការឲ្យមានការស្តាប់ចម្លើយសារជាថ្មី ឬឲ្យមានការតទល់គ្នា។ ភាពផ្ទុយគ្នានេះ ក៏អាចត្រូវបានបំភ្លឺផងដែរនៅដំណាក់កាលនៃសវនាការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៥. ក្នុងករណីនេះ ដោយបានសង្កេតឃើញពីភាពខុសគ្នារវាងការផ្តល់សក្ខីកម្មជាបន្តបន្ទាប់របស់សាក្សីដែលបានលើកឡើងនេះ សហចៅក្រមស៊ើបអង្កេត បានសម្រេចឲ្យមានការស្តាប់ចម្លើយសាក្សីរូបនេះសារជាថ្មី ក្នុងគោលបំណងដូចជា បំភ្លឺចំណុចមួយចំនួនដែលមាននៅក្នុងកំណត់ហេតុកន្លងមក។ កំណត់ហេតុនៃការស្តាប់ចម្លើយនេះ នឹងដាក់ចូលទៅក្នុងសំណុំរឿងក្នុងពេលឆាប់ៗខាងមុខ។

៦. ក្រៅពីនេះចំណុចដែលរៀបរាប់ខាងលើ សំណើសុំនេះ ក៏ផ្តល់ជាឱកាសមួយដើម្បីឲ្យសហចៅក្រមស៊ើបអង្កេត រំលឹកឡើងវិញពីគោលការណ៍ដែលកំណត់ពីនីតិវិធី ដែលត្រូវអនុវត្តនៅ អ.វ.ត.ក។

៧. ដូចយើងធ្លាប់បានបញ្ជាក់ចំពោះសហព្រះរាជអាជ្ញា[2]រួចមកហើយថា នីតិវិធីជាធរមានដែលអនុវត្តនៅ អ.វ.ត.ក នៅក្នុងដំណាក់កាលនៃការស៊ើបសួរ គឺជានីតិវិធីសរសេរ៖ នៅពេលបញ្ចប់នៃការស្តាប់ចម្លើយនីមួយៗ តែងតែមានការតាក់តែងកំណត់ហេតុនៃការស្តាប់ចម្លើយនៅក្នុងលក្ខខណ្ឌទំរង់ ដូចមានកំណត់នៅ ក្នុងវិធាន ៥៥(៧)។ ជាក់ស្តែង ខ្លឹមសារទាំងមូលនៃកំណត់ហេតុនៃការស្តាប់ចម្លើយនេះ នឹងត្រូវគេអានឱ្យសាក្សីស្តាប់មុននឹងសាក្សីនោះចុះហត្ថលេខាលើទំព័រនីមួយៗនៃកំណត់ហេតុ[3]។ រហូតដល់មានការលើកឡើងនូវភស្តុតាងផ្ទុយ កំណត់ហេតុនៃការស្តាប់ចម្លើយទាំងនេះ ដែលគេសន្មតថា គឺជាអ្វីដែលសាក្សីបានពោលអះអាងនឹងត្រូវដាក់ចូលក្នុងសំណុំរឿង។ សំណុំរឿងដែលទទួលបាននេះ គឺជាមូលដ្ឋានគ្រឹះនៃនីតិវិធីផ្ទាល់មាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលមានការបញ្ជូនរឿងទៅជំនុំជម្រះ។

៨. គឺនៅក្នុងបរិបទបែបនេះហើយ ដែលយើងធ្វើការបកស្រាយវិធាន ២៥(៤) នៃវិធានផ្ទៃក្នុងមានន័យថា សហចៅក្រមស៊ើបអង្កេតអាចសម្រេចអនុវត្តចំពោះការស្តាប់ចម្លើយសាក្សីនូវវិធាន ២៥(១) ដែលទាក់ទងនឹងការថតយកសម្លេង និងរូបភាពក្នុងពេលសួរយកចម្លើយជនត្រូវចោទ។

៩. នៅក្នុងការអនុវត្ត សហចៅក្រមស៊ើបអង្កេតបានសម្រេចអនុវត្តបទប្បញ្ញត្តិនេះជាស្វ័យប្រវត្តិ។ ការសម្រេចបែបនេះស្តែងចេញឡើងតាមរយៈពាក្យពេចន៍ ដែលមាននៅក្នុងអត្ថបទនៃដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលធ្វើឡើងដើម្បីប្រមូលភស្តុតាង។ អ្នកស៊ើបអង្កេតនៃ អ.វ.ត.ក បានអនុវត្តតាមខ្លឹមសារនៃដីកាទាំងនេះ លើកលែងតែក្នុងករណី ដែលពួកគេត្រូវបានរំខានដោយកាលៈទេសៈពិសេសណាមួយតែប៉ុណ្ណោះ។

១០. ទោះបីជាយ៉ាងនេះក្តី ក៏ការថតយកសម្លេង និងរូបភាព មិនមែនត្រូវបានគេធ្វើឡើងដើម្បីជំនួសឱ្យការតាក់តែងកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយល័ក្ខណ៍អក្សរ ដែលត្រូវដាក់ចូលក្នុង

---

[2] សំណុំរឿងលេខ ០០១-D91 ថ្ងៃ ៣០ ឧសភា ២០០៨

[3] វិធាន ៥៥ (៧) *"រាល់ការស្តាប់ចម្លើយ ឬសួរយកចម្លើយទាំងអស់របស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុ។ គ្រប់ទំព័រទាំងអស់នៃកំណត់ហេតុត្រូវមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃក្រោយពេលអ្នកដែលឆ្លើយនោះអានរួចហើយ។ ក្នុងករណីចាំបាច់ ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដោយមានជំនួយពីអ្នកបកប្រែត្រូវអានកំណត់ហេតុនេះឡើងវិញ។ ប្រសិនបើអ្នកដែលឆ្លើយនោះមិនព្រមចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេតត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។"*

សំណុំរឿង ឬដើម្បីកែប្រែនីតិវិធីស៊ើបសួរឱ្យក្លាយជានីតិវិធីផ្ទាល់មាត់នោះឡើយ។ អនុលោមតាមវិធាន ២៥(១)(ឆ) *"ឯកសារថតយកសម្លេង ឬរូបភាពទាំងនេះអាចត្រូវប្រើក្នុងករណីមានការប្រកែកជំទាស់អំពីភាពត្រឹមត្រូវនៃកំណត់ហេតុសួរយកចម្លើយជាលាយលក្ខណ៍អក្សរ"* មានន័យថា គោលបំណងចម្បងរបស់បញ្ញត្តិនេះ គឺធ្វើឡើងដើម្បីការពារសាក្សីដែលបានផ្តល់សក្ខីកម្ម ក្នុងករណីដែលសាក្សីរូបនេះយល់ថា កំណត់ហេតុមិនស្របទៅនឹងអ្វីដែលខ្លួនបាននិយាយ ដូច្នេះ ការថតយកសម្លេង និងរូបភាពនេះ មិនមែនធ្វើឡើងក្នុងគោលបំណងដើម្បីជាដំណោះស្រាយចំពោះភាពផ្ទុយគ្នា ដែលកើតមានឡើងរវាងកំណត់ហេតុផ្សេងៗខុសគ្នានោះទេ។ ដូចជាក្នុងករណីដែលយើងកំពុងពិនិត្យនេះជាដើម។

១១. វាជាសិទ្ធិអំណាចរបស់ចៅក្រមក្នុងការវាយតម្លៃមួយករណីម្តងៗអំពីផលប្រយោជន៍ក្នុងការតម្រូវឱ្យមានអត្ថបទប្រតិចារឹត និងអត្ថបទបកប្រែមួយផ្នែក ឬទាំងមូលនៃការថតយកសម្លេង ឬរូបភាពដែលមាន។ ចំពោះរឿងដែលថា វិធាន ២៥(១)(ជ) ទទួលស្គាល់ដល់សហព្រះរាជអាជ្ញា និងភាគីដ៏ទៃទៀត នូវសិទ្ធិក្នុងការស្នើសុំថតចម្លងការថតយកសម្លេង ឬរូបភាព នឹងមិនមែនជាបញ្ហាដែលនាំឱ្យប៉ះពាល់ដល់សារជាតិសរសេរនៃនីតិវិធីនោះឡើយ៖ ប្រសិនណាបើមិនមានការជំទាស់របស់បុគ្គលដែលត្រូវបានស្តាប់ចម្លើយនោះទេ កំណត់ហេតុនៃការស្តាប់ចម្លើយគឺជារបាយការណ៍ផ្លូវការនៃការស្តាប់ចម្លើយនោះ ហើយភាពត្រឹមត្រូវលើខ្លឹមសាររបស់វា នឹងអាចត្រូវបានជំទាស់ដោយតតិយជនតែក្នុងករណីដែលមានការលើកឡើងនូវភស្តុតាងផ្ទុយតែប៉ុណ្ណោះ។ ហេតុដូច្នេះ លើកលែងតែមានការជំទាស់ ដែលធ្វើឡើងដោយសាក្សីចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយរបស់ខ្លួន អ.វ.ត.កមិនមានកាតព្វកិច្ចក្នុងការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំអត្ថបទប្រតិចារឹត ឬអត្ថបទបកប្រែ ដែលធ្វើឡើងដោយតតិយជននោះឡើយ ដោយសារថាភាគីអាចរកបាននូវគ្រប់ការថតយកសម្លេងទាំងអស់ (ដែលជាគោលការណ៍ធ្វើឡើងក្នុងភាសាណាមួយក្នុងចំណោម ភាសារបស់ អ.វ.ត.ក) ក្នុងទំរង់ជាអេឡិកត្រូនិកនៅក្នុង Zylab[4]។ ក្នុងន័យនេះ ភាគីអាចនឹងទទួលបានឯកសារដោយផ្ទាល់នៅគ្រប់ពេលវេលាទាំងអស់ ដោយមិនចាំបាច់ធ្វើការស្នើសុំ។

[4] ជាពិសេសឯកសារដែលជាកម្មវត្ថុនៃសំណើសុំនេះ៖ D25/24R, TR00239707; D94/14R, TR00210130: អាចរកបាននៅលើទំព័រមុខទី ០១ របស់ Zylab (ដោយយកលេខយោងដូចនឹងរបស់ឯកសារថតសម្លេងផងដែរ)។

១២. ជាចុងបញ្ចប់ ផ្ទុយទៅនឹងអ្វីដែលបានលើកឡើងដោយក្រុមមេធាវីការពារក្តីនៅក្នុងកថាខណ្ឌ ០៧ នៃសំណើសុំរបស់ខ្លួន ព័ត៌មាន *"ដោះបន្ទុក"* ជនត្រូវចោទមិនត្រូវបានគេ *"ដកចេញ"* ពីក្នុងរបាយការណ៍អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសចុះថ្ងៃ ៣១ មីនា ២០០៨ នោះឡើយ។ កម្មវត្ថុចម្បងនៃការតាក់តែងរបាយការណ៍នេះ គឺដើម្បីរៀបរាប់អំពីស្ថានភាពវិវត្តជាក់ស្តែងនៃដំណើរការកិច្ចស៊ើបសួរតែប៉ុណ្ណោះ រីឯភស្តុតាងទាំងអស់ទាំងដាក់បន្ទុក ឬដោះបន្ទុក គឺមានក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយផ្ទាល់ និងដែលមានភ្ជាប់មកជាមួយនឹងរបាយការណ៍។

## ហេតុដូច្នេះសម្រេច

**បដិសេធ** សំណើសុំឱ្យមានការរៀបចំធ្វើអត្ថបទប្រតិចារឹត និងការបកប្រែទៅជាភាសាអង់គ្លេសនូវកំណត់ហេតុនៃការស្តាប់ចម្លើយខាងលើ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

យូ ប៊ុនឡេង Marcel LEMONDE